**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**
**អគ្គនាយកដ្ឋានរដ្ឋបាល**
**នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល**

លេខ......................ន.ប.ប

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០១៦

**សូមគោរពជូន**

- **ឯកឧត្តម អគ្គាធិការ នៃអគ្គាធិការដ្ឋាន**
- **ឯកឧត្តម អគ្គនាយក រដ្ឋបាល**
- **ឯកឧត្តម អគ្គនាយក ប្រៃសណីយ៍ និងទូរគមនាគមន៍**
- **ឯកឧត្តម អគ្គនាយក បច្ចេកវិទ្យា គមនាគមន៍ និង ព័ត៌មាន**
- **ឯកឧត្តម ប្រធានវិទ្យាស្ថានជាតិប្រៃសណីយ៍ និងទូរគមនាគមន៍ បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន**
- **លោកប្រធាននាយកដ្ឋាន សវនកម្មផ្ទៃក្នុង**
- **លោក លោកស្រី ប្រធានមន្ទីរ ប្រៃសណីយ៍ និងទូរគមនាគមន៍**

**<u>កម្មវត្ថុ</u>** : ស្តីពីការផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលនៅប្រទេសឥណ្ឌាជូនមន្ត្រីរាជការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍សម្រាប់ឆ្នាំសិក្សា ២០១៦-២០១៧។

**<u>យោង</u>** : -លិខិតលេខPHN/ITEC/237/1/2016 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ របស់ស្ថានទូតឥណ្ឌាប្រចាំនៅកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជូន **ឯកឧត្តម អគ្គាធិការ ឯកឧត្តម អគ្គនាយក ឯកឧត្តមប្រធានវិទ្យាស្ថាន** និង **លោក លោកស្រីប្រធាន** ជ្រាបថា៖ ក្រោមកម្មវិធី Indian Technical and Economic (ITEC) រដ្ឋាភិបាលឥណ្ឌាបានផ្សព្វផ្សាយសាជាថ្មី ដោយផ្តល់វគ្គបណ្តុះបណ្តាលជំនាញក្នុងវិស័យ Telecom Technology and Management ជូនមន្ត្រីរាជការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (**ក្នុង ០១វគ្គ ចំនួន០២រូប**) សម្រាប់ឆ្នាំសិក្សា ២០១៦-២០១៧ នៅទីក្រុង Mumbai ប្រទេសឥណ្ឌា។ សម្រាប់លក្ខខណ្ឌចូលរួមវគ្គបណ្តុះបណ្តាលខាងលើនេះមានដូចខាងក្រោម៖

១-បេក្ខជនត្រូវមានចំណេះដឹងភាសាអង់គ្លេសសមរម្យ

២-បេក្ខជនពុំធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលរបស់ ITEC ពីមុន

៣-ត្រូវមានអាយុចន្លោះពី **២៥ឆ្នាំ ដល់ ៤៥ឆ្នាំ**

៤-ត្រូវបំពេញបែបបទOnline តាមគេហទំព័រ http://www.itecgoi.in រួចបន្ទាប់មកបោះពុម្ព (print) ទុកជាឯកសារសំណុំបែបបទនេះចំនួន **០៣ច្បាប់** (បញ្ជូនមកនាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាល)

៥-បេក្ខជនត្រូវអានសេចក្តីណែនាំដែលមានក្នុងសំណុំបែបបទអោយបានច្បាស់លាស់មុននឹងដាក់ពាក្យចូលរួមវគ្គសិក្សា។

អាស្រ័យហេតុដូចបានគោរពជូនខាងលើ សូម **ឯកឧត្តម** និង **លោក លោកស្រីប្រធាន** មេត្តាជួយផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលខាងលើជូនដល់មន្ត្រីក្រោមឱវាទដែលមានចំណាប់អារម្មណ៍ដាក់ពាក្យចូលរួម និងពិសេសជម្រុញមន្ត្រីដែលធ្វើការពាក់ព័ន្ធវិស័យខាងលើ(មានឯកសារព័ត៌មានលម្អិត និងវគ្គនីមួយៗ ភ្ជាប់ជូន)។ សូម **ឯកឧត្តម** និង **លោក លោកស្រីប្រធាន** មេត្តាបញ្ជូនព័ត៌មានបេក្ខជនចូលរួមទាំងអស់ និងចម្លងឯកសារដែលបេក្ខជនបានបំពេញបែបបទOnlineរួច មកនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលឱ្យបាន **០៣ខែ** មុនការចាប់ផ្តើមវគ្គសិក្សានីមួយៗ ដើម្បីឱ្យនាយកដ្ឋានធ្វើការរាយការណ៍ជូនថ្នាក់ដឹកនាំ និងឆ្លើយតបទៅស្ថានទូត។

សូម **ឯកឧត្តម** និង **លោក លោកស្រីប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។៚

**ប្រធាននាយកដ្ឋានស្តីទី**

**ជួន ដារ៉ូ**

*<u>ចម្លងជូន៖</u>*

*-ខុទ្ទកាល័យ*

*-ថ្នាក់ដឹកនាំក្រសួងប.ទ*

*"ដើម្បីជូនជ្រាប"*